អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងប្រកាសរបៀបវារៈសម្រាប់សវនាការបឋមក្នុងសំណុំរឿង ០០២

អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រកាសថា សវនាការបឋមនៅក្នុងសំណុំរឿងវគ្គទីពីររបស់តុលាការ ដែលបានកំណត់ធ្វើឡើងពីថ្ងៃទី២៧ ដល់ទី៣០ ខែមិថុនា នឹងចាប់ផ្តើមនៅម៉ោង ៩:០០ ព្រឹក និងបញ្ចប់នៅម៉ោង ៤:០០ រសៀលជារៀងរាល់ថ្ងៃ ហើយនឹងស្តាប់អំណះអំណាងផ្ទាល់មាត់ស្តីពីអញ្ញត្រកម្ម ក្នុងចំណោមបញ្ហាផ្សេងៗទៀត។

**កាលវិភាគបណ្តោះអាសន្ន**

| **កាលបរិច្ឆេទ** | **ម៉ោង** | **របៀបវារៈ** |
|---|---|---|
| ថ្ងៃច័ន្ទទី២៧ ខែមិថុនា | ៩:០០ - ១៦:០០ | ១.**ការផ្តល់បញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន** សម្រាប់ដំណាក់កាលទី១ នៃការជំនុំជម្រះ<br><br>២.**អញ្ញត្រកម្មស្តីពីការមិនកាត់ទោសពីរដងលើបទល្មើសតែមួយ៖** អតិបរមា ២ ម៉ោងកន្លះ (មេធាវីការពារ អៀង សារី ការិយាល័យសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី)<br><br>៣.**អញ្ញត្រកម្មស្តីពីការបន្ធូរបន្ថយទោស/ការលើកលែងទោស៖** ២ ម៉ោងកន្លះ (មេធាវីការពារ អៀង សារី ការិយាល័យសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី) |
| ថ្ងៃអង្គារទី២៨ ខែមិថុនា | ៩:០០ - ១៦:០០ | ៤.**អញ្ញត្រកម្មស្តីពីអាជ្ញាយុកាលពាក់ព័ន្ធនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ៖** ២ ម៉ោងកន្លះ (មេធាវីការពារ អៀង សារី ការិយាល័យសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី) |

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

Original EN: 01699224-01699226

| | | |
|---|---|---|
| | | **៥.អញ្ញត្រកម្មស្តីពីអាជ្ញាយុកាលពាក់ព័ន្ធនឹងបទល្មើសនានាដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦៖** ៤ ម៉ោងកន្លះ (មេធាវីការពារក្តីទាំងអស់ ការិយាល័យសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី) |
| ថ្ងៃពុធទី២៩ ខែមិថុនា | ៩:០០ - ១៦:០០ | **៦.អញ្ញត្រកម្មស្តីពីពាក់ព័ន្ធនឹងបទល្មើសនានាដែលមានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៥៦៖** បន្តពីថ្ងៃអង្គារទី២៨ ខែមិថុនា<br><br>**៧.សេចក្តីបញ្ជាក់បឋមអំពីខ្លឹមសារនៃសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី** ៖ អតិបរមា ១ ម៉ោង (សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី) |
| ថ្ងៃព្រហស្បត្តិ៍ទី៣០ ខែមិថុនា | ៩:០០ - ១៦:០០ | ៨.អំណះអំណាងផ្ទាល់មាត់ពាក់ព័ន្ធនឹង**ការជំទាស់ទៅនឹងបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើង ប្រសិនបើមាន** |

សម្រាប់ព័ត៌មានលម្អិតនៃរបៀបវារៈ សូមមើលរបៀបវារៈសម្រាប់សវនាការបឋម៖ https://www.eccc.gov.kh/en/document/court/agenda-initial-hearing-27th-30th-june-2011

បន្ទាប់ពីសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចទៅនឹងបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញស្តាពរ សម្រាប់ដំណាក់កាលដំបូងនៃការជំនុំជម្រះ ហើយនឹងកំណត់ពេលចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅពេលក្រោយ។

ក្រៅពីនេះ អង្គជំនុំជម្រះសាលាដំបូងអាចនឹងកំណត់ពេលសវនាការបន្ថែមទៀតនៅខែសីហា ឆ្នាំ២០១១ មុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី។ ព័ត៌មានលម្អិតពាក់ព័ន្ធនឹងសវនាការទាំងនេះនឹងផ្តល់ជូនជាក្រោយក្នុងពេលវេលាសមស្រប។

## ការណែនាំសម្រាប់ភ្ញៀវដែលអញ្ជើញមកចូលរួមសវនាការ

សវនាការបឋមនៅខែមិថុនា ធ្វើឡើងជាសាធារណៈសម្រាប់សាធារណជនទូទៅ។ ដើម្បីធានាសណ្តាប់ធ្នាប់នៅក្នុងតុលាការ ក្នុងអំឡុងពេលសវនាការ តុលាការបានរៀបចំកន្លែងអង្គុយនៅសាលសាធារណៈចំនួន ៤៨២ កៅអី។

កៅអីចំនួន ៤០ នឹងបម្រុងទុកសម្រាប់សាធារណជន ចំណែកកៅអី ១០០ ត្រូវបានបម្រុងទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និង កៅអីចំនួន ២២០ ផ្សេងទៀតបម្រុងទុកសម្រាប់ពលរដ្ឋកម្ពុជាទូទៅ ទៅតាមការរៀបចំ និងអមដំណើរដោយ អ.វ.ត.ក។ កៅអីមួយចំនួនក៏បម្រុងទុកសម្រាប់ដៃគូអង្គការក្រៅរដ្ឋាភិបាល មន្ត្រីការទូត មន្ត្រីរដ្ឋាភិបាល និងអ្នកស្រាវជ្រាវល្បីៗ។ តម្រូវឲ្យមានការចុះឈ្មោះជាមុនសម្រាប់កៅអីទាំងអស់ លើកលែងតែសាធារណជន។ សូមទាក់ទងទៅ៖ pas@eccc.gov.kh។ កាលបរិច្ឆេទចុងក្រោយនៃការចុះឈ្មោះគឺត្រឹមថ្ងៃច័ន្ទទី២០ ខែមិថុនា។

អ.វ.ត.ក សំណូមពរដល់ភ្ញៀវមេត្តាអញ្ជើញមកដល់មាត់ទ្វាសន្តិសុខចាប់ពីម៉ោង ៧:៣០ នាទី ដល់ ៨:០០ ព្រឹក ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យសន្តិសុខ និងចេញលិខិតជូន។ ទ្វានៅបន្ទប់សវនាការនឹងបិទត្រឹមម៉ោង ៨:៤៥ នាទីព្រឹក ឬនៅពេលភ្ញៀវចូលមកអង្គុយពេញកៅអីនៅកន្លែងសម្រាប់សាធារណជន។

សូមជម្រាបជូនដំណឹងផងដែរថា ភ្ញៀវទាំងអស់ត្រូវបង្ហាញអត្តសញ្ញាណ (មានបិទរូបថត) នៅមាត់ទ្វា។ អ្នកដែលមានអាយុក្រោម ១៦ ឆ្នាំនឹងមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងសវនាការទេ ហើយអ្នកមានអាយុពី ១៦ ដល់ ១៨ ឆ្នាំ អាចអនុញ្ញាតឲ្យចូលបាន លុះត្រាតែមានអាណាព្យាបាលជាមនុស្សពេញវ័យមកជាមួយ។ ភ្ញៀវត្រូវរក្សាសេចក្តីថ្លៃថ្នូរ និងមានឥរិយាបថសមរម្យគ្រប់ពេលវេលា ហើយត្រូវស្លៀកពាក់សម្លៀកបំពាក់ឲ្យបានសមរម្យ។ ទូរស័ព្ទដៃ កាបូបធំៗ ចំណីអាហារ ភេសជ្ជៈ មិនត្រូវបានអនុញ្ញាតឲ្យយកចូលក្នុងសាលសាធារណៈទេ។

អ.វ.ត.ក មានទីតាំងស្ថិតនៅសង្កាត់ចោមចៅ រាជធានីភ្នំពេញ ចម្ងាយ ១៦ គ.ម ពីរាជធានី តាមបណ្តោយផ្លូវជាតិលេខ ៤ ឆ្ពោះទៅក្រុងព្រះសីហនុ។ សូមសាធារណជន និងអ្នកយកសារព័ត៌មាន មេត្តាចូលតាមច្រកទ្វាសម្រាប់ភ្ញៀវ នៅប៉ែកខាងកើតបរិវេណតុលាការ។ មានការផ្តល់ជូនចំណតយានយន្តសម្រាប់ភ្ញៀវដែលមានយានយន្តផ្ទាល់ខ្លួន។

**យោបល់ណែនាំសម្រាប់សារព័ត៌មាន**

ការចុះឈ្មោះជាមុន និងការទទួលបានបណ្ណអនុញ្ញាតជាមុន គឺជាការចាំបាច់សម្រាប់តំណាងសារព័ត៌មានទាំងអស់ដែលមានបំណងទទួលការអនុញ្ញាតឲ្យចូលក្នុងបរិវេណ អ.វ.ត.ក នៅថ្ងៃទី២៧-៣០ ខែមិថុនា ឆ្នាំ ២០១១។ នីតិវិធីដូចខាងក្រោមនឹងអនុវត្តចំពោះតំណាងសារព័ត៌មាន ដែលស្នើសុំចូលបរិវេណ អ.វ.ត.ក សម្រាប់សវនាការបឋម៖

ក) **អ្នកមានបណ្ណអនុញ្ញាតសម្រាប់សារព័ត៌មាននៅ អ.វ.ត.ក ដែលមានសុពលភាព** ត្រូវដាក់សំណើសុំចូលស្តាប់សវនាការបឋម ទៅផ្នែកកិច្ចការសាធារណៈ ដោយផ្ញើអ៊ីមែលទៅ pas@eccc.gov.kh។

ខ) **អ្នកមានបណ្ណអនុញ្ញាតសម្រាប់សារព័ត៌មាននៅ អ.វ.ត.ក ដែលផុតសុពលភាព** ត្រូវបំពេញទម្រង់បែបបទស្នើសុំបណ្ណអនុញ្ញាតសម្រាប់សារព័ត៌មានឲ្យបានពេញលេញ មានចុះហត្ថលេខា និងដាក់សំណើសុំចុះឈ្មោះទៅ pas@eccc.gov.kh។ សូមបង្ហាញលេខកាតនៅលើបណ្ណអនុញ្ញាតសម្រាប់ អ.វ.ត.ក របស់អ្នកដែលផុតសុពលភាព។

គ) **អ្នកពុំមានបណ្ណអនុញ្ញាតសម្រាប់សារព័ត៌មាននៅ អ.វ.ត.ក** ត្រូវបំពេញទម្រង់បែបបទស្នើសុំបណ្ណអនុញ្ញាតសម្រាប់សារព័ត៌មានឲ្យបានពេញលេញ មានចុះហត្ថលេខា រូបថតបញ្ឈរជាទម្រង់ jpg មួយសន្លឹក និងច្បាប់ថតចម្លងលិខិតឆ្លងដែន រួមជាមួយពាក្យសុំចុះឈ្មោះ ដាក់ជូនទៅ pas@eccc.gov.kh។

ទម្រង់បែបបទស្នើសុំបណ្ណអនុញ្ញាតសម្រាប់សារព័ត៌មានអាចទាញយកបានពីគេហទំព័រ អ.វ.ត.ក៖
www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_Application_Form.doc.

កៅអីដល់ទៅចំនួន ៣០ នៅសាលសាធារណៈនៃបន្ទប់សវនាការត្រូវបានបម្រុងទុកសម្រាប់តំណាងសារព័ត៌មាន។ យើងផ្តល់អាទិភាពដល់សារព័ត៌មានបោះពុម្ពផ្សាយ។ តំណាងសារព័ត៌មានផ្សេងទៀតនឹងទៅអង្គុយនៅក្នុងបន្ទប់សារព័ត៌មាន ជាន់ផ្ទាល់ដី។ តំណាងសារព័ត៌មានដែលមានបំណងចង់ទៅអង្គុយនៅក្នុងសាលសាធារណៈគួរដាក់ពាក្យស្នើសុំកក់កៅអីឲ្យបានត្រឹមថ្ងៃទី២០ ខែមិថុនា។

**កាលបរិច្ឆេទចុងក្រោយសម្រាប់ស្នើសុំចុះឈ្មោះ និងបណ្ណអនុញ្ញាតសម្រាប់សារព័ត៌មានគឺត្រឹម៖ ថ្ងៃពុធ ទី២២ ខែមិថុនា ឆ្នាំ២០១១**

សម្រាប់ព័ត៌មានបន្ថែមស្តីពីសេវា និងអាគារសម្រាប់សារព័ត៌មាន សូមចូលមើល៖
https://www.eccc.gov.kh/en/articles/media-advisory-initial-hearing

អ.វ.ត.ក នឹងបើកទ្វារអគារសម្រាប់ឲ្យសារព័ត៌មានដែលមានបំណងមកតាមឡើងបរិក្ខារនៅថ្ងៃចុងសប្តាហ៍ទី ២៥-២៦ ខែមិថុនា ហើយនឹងរៀបចំ**ផ្តល់ការពន្យល់ខ្លីៗមុនសវនាការនៅម៉ោង ២ រសៀលថ្ងៃអាទិត្យទី២៦ ខែមិថុនា។**

សម្រាប់ព័ត៌មានបន្ថែមស្តីពីសនាការបឋម សូមទាក់ទង៖


**លោក ឌីម សុវណ្ណារ៉ុម**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទ៖ +៨៥៥-១២ ៤៨៨ ០៩៤
ទូរសារ៖ +៨៥៥-២៣ ២១៩ ៨៤១
អ៊ីមែល៖ dim.sovannarom@eccc.gov.kh

**លោកស្រី Yuko Maeda**
មន្ត្រីផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទ៖ +៨៥៥-១២ ៤៨៨ ៣១៩
ទូរស័ព្ទលើតុ៖ +៨៥៥ ២៣ ២១៩ ៨១៤ លេខបន្ត ៦១៣៩
អ៊ីមែល៖ maeday@un.org

**លោក ហ៊ុយ វណ្ណៈ**
មន្ត្រីផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទ៖ +៨៥៥-១២ ៣៣៩ ៤២៧
ទូរស័ព្ទលើតុ៖ +៨៥៥-២៣ ២១៩ ៨៤១
អ៊ីមែល៖ huy.vannak@eccc.gov.kh